ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០១០.......សហវ.......

# សារាចរណែនាំ

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី១ ជំហានទី៣ និងការកែសម្រួលនីតិវិធីរៀបចំសលាកបត្របង់ចំណូលថវិកាជាតិ

អនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលបានដាក់ឱ្យអនុវត្តរួចរាល់នៅដំណាក់កាលទី១ ជំហានទី១ និងជំហានទី២ សម្រាប់រដ្ឋបាលកណ្ដាល រួមមាន ក្រសួង ស្ថាប័ន ចំនួន ២៣ តាមរយៈសារាចរណែនាំលេខ០០៣ សហវ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ និងសារាចរណែនាំលេខ០០៨ សហវ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅក្នុងដំណាក់កាលទី១ ជំហានទី៣ នេះ ប្រព័ន្ធNRMIS នឹងដាក់ឱ្យអនុវត្តសម្រាប់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ចំនួន១៨ រួមមាន÷ រដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, មន្ទីរព័ត៌មាន, មន្ទីរសុខាភិបាល, មន្ទីររ៉ែនិងថាមពល, មន្ទីរពាណិជ្ជកម្ម, មន្ទីរអប់រំ យុវជន និងកីឡា, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ, មន្ទីរបរិស្ថាន, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍, មន្ទីរសាធារណការនិងដឹកជញ្ជូន, សាលាដំបូង, មន្ទីរទេសចរណ៍, មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី, មន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមន្ទីរឧស្សាហកម្មនិងសិប្បកម្ម។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តរៀបចំលេខកូដចំណូលមិនមែនសារពើពន្ធជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងដំណាក់កាលបន្តបន្ទាប់។

មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ទាំង១៨ ខាងលើ ត្រូវប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធដែលបានកំណត់ដោយលម្អិតទៅតាមចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត។ គ្រប់ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិទាំងអស់ ដែលអាចប្រមូល និងបង់ចូលថវិការដ្ឋបាន លុះត្រាតែមានលេខកូដចំណូលដែលអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋាន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

រតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) តាមការស្នើសុំរបស់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទក្រសួង ស្ថាប័នអាណាព្យាបាល។ លេខកូដចំណូលមិនមែនសារពើពន្ធនៃមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នីមួយៗ ត្រូវអនុវត្តតាមលេខកូដចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័ន អាណាព្យាបាល។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) សម្រាប់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ទាំង ១៨ ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចដាក់ចេញនូវសេចក្តីណែនាំ អំពីនីតិវិធីនៃការប្រមូលនិងកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងការបង់ចំណូលទៅសាខាធនាគារពាណិជ្ជដៃគូ ដូចខាងក្រោម÷

១.ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធNRMIS÷ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។

២.ពេលបង់ចំណូលទៅសាខាធនាគារពាណិជ្ជដៃគូ÷

-ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជនដើម្បីបង់ប្រាក់នៅសាខាធនាគារពាណិជ្ជដៃគូ

-ចំពោះចំណូលពីសេវាសាធារណៈ÷ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន ០២ច្បាប់ ដោយ ០១ច្បាប់ រក្សាទុកជូនសាខាធនាគារពាណិជ្ជដៃគូ និង ០១ច្បាប់ទៀតរក្សាទុកដោយរដ្ឋទេយ្យករចំណូល ឬ គណនេយ្យករចំណូលរបស់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្តសាមី ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬ បង្វែរ (គណនីចរន្តរបស់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត) ចូលគណនីទោលរតនាគារ (TSA) នៅរាជធានី ខេត្ត

-ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត អាចអនុវត្តតាមនីតិវិធីនៃការបង់ចំណូល ចំពោះចំណូលពីសេវាសាធារណៈ ឬ ចំណូលពីទ្រព្យសម្បត្តិរដ្ឋតាមយថាប្រភេទនៃចំណូលជាក់ស្តែង

-ក្រោយពីបានបង់ប្រាក់ចូល TSA មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវកត់ត្រាលេខយោងលើបណ្ណបង់ប្រាក់ (Bank Slip) ឬ ប្រកាសឥណពន្ធ (Debit Advice) ឬ បណ្ណផ្ទេរប្រាក់/ ឥណទាន (Remittance Slip) ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការនៃការបោះពុម្ពវិក្កយបត្រ ដោយត្រូវបញ្ចូលអត្រាប្តូរប្រាក់តាមអត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា)។

៣.ការបង្វែរចំណូលចូលថវិកាជាតិ÷

-មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ជ្រើសរើសយកប្រតិបត្តិការដែលបានបង់ចូល TSA ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិកាជាតិចេញពីប្រព័ន្ធ NRMIS

-រដ្ឋទេយ្យករចំណូល ឬ គណនេយ្យករចំណូលត្រូវពិនិត្យសលាកបត្របង់ចំណូលថវិកាជាតិ ដែលទាញចេញពីប្រព័ន្ធ NRMIS រួចបញ្ជូនមករតនាគាររាជធានី ខេត្ត ជាមុន ក្នុងទម្រង់ជាអេឡិកត្រូនិក តាមរយៈប្រព័ន្ធអេឡិកត្រូនិក ដោយមិនតម្រូវឱ្យបោះពុម្ពចេញនិងចុះហត្ថលេខានោះទេ ប៉ុន្តែត្រូវរៀបចំនិងចុះហត្ថលេខាលើដីកាសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ (ដូចមានគំរូភ្ជាប់ជូន) និងផ្ញើជូនរតនាគាររាជធានី ខេត្ត ជាប្រចាំខែវិញ (ក្នុងករណីមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មានសលាកបត្របង់ចំណូលថវិកាជាតិតិចតួច អាចបោះពុម្ពសលាកបត្របង់ចំណូលថវិកាជាតិដែលផលិតចេញពីប្រព័ន្ធ NRMIS និងចុះហត្ថលេខា រួចបញ្ជូនមករតនាគាររាជធានី ខេត្ត តែម្តង ដោយមិនចាំបាច់រៀបចំដីកាសម្រង់សលាកបត្របង់ចំណូលថវិកាជាតិទេ)។

៤. ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត បានបុរេប្រទានពីថវិកាជាតិកន្លងមក មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវប្រើប្រាស់ប្រព័ន្ធ NRMIS ជាមូលដ្ឋាន ដោយត្រូវជ្រើសរើសយកសលាកបត្របង់ចំណូលថវិកាជាតិ ដែលបានបង្វែរចូលថវិកាជាតិ ឬ ដីកាសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ តាមរយៈសាច់ប្រាក់ដែលបានបង់ចូល (TSA)។ បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និងរបាយការណ៍ស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់, តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក និងផ្ញើរមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីអនុវត្តនីតិវិធីបន្ត។

បន្ទាប់ពីទទួលបានសារាចរណែនាំនេះ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងសាខាធនាគារពាណិជ្ជដៃគូ របស់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្តសាមី ឱ្យប្រើប្រាស់លេខកូដសម្រាប់ការបង់ចំណូលជាកំហិត។

មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ទាំង១៨ ខាងលើ ត្រូវអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

“ដើម្បីជូនជ្រាប”

- -ក្រសួង ស្ថាប័នអាណាព្យាបាលនិងមន្ទីរ អង្គភាពជំនាញទាំង១៨ គ្រប់រាជធានី ខេត្ត
- -អគ្គនាយកដ្ឋានរតនាគារជាតិ
- -អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- -រតនាគាររាជធានី ខេត្ត

“ដើម្បីអនុវត្ត”

- -ឯកសារ-កាលប្បវត្តិ